មេប៉ូលិសរវេភ្នែករំពៃរកមើលនាយស័ក្តិប្អូនគ្រប់ទីកន្លែង តែមិនឃើញស្រមោលរបស់គេ។ លោកជំទាវសម្លក់អ្នកទាំងពីរ ហើយដើរចេញទាំងនិយាយរអ៊ូ៖

«អង្គរក្សហ្នឹងមានគ្នាប៉ុន្មាន? បើកូន Royមកមិនទាន់ ស្មានថាគេហ្នឹងធ្វើអីបានខ្លះជួយជីវិតកូន?»

ឪពុកអមរាជាញាក់ភ្នែកដាក់កូនស្រី ធ្វើឲ្យនាងញញឹមខ្ទឹបហើយត្រៀមចាកចេញប្រញាប់ប្រញាល់៖

«កូនចង់ឡើងទៅរកថ្នាំ!»

នាងរត់ឡើងទៅទាំងធ្វើមុខប្រឡឹម មិនហ៊ានមើលទៅជំទាវម្តាយរបស់ខ្លួនព្រោះនាងដឹងថាគាត់នៅតែមិនពេញចិត្តចំពោះការខ្វែងគំនិតនេះ។

«គង់តែខូចកូនអស់ទេ!»

សំឡេងគាត់បន្ទោសលោកប្តីលាន់មកពីក្រោយខ្នងនារីតូច។

…..ចិត្រាកំពុងតែព្យាយាមទូរសព្ទទាក់ទងឯកមានផង កែងដៃបណ្តោយឲ្យពូហឿនលាបរបួសឲ្យបណ្តើរផង...

«ជាំខៀវអស់ហើយក្មួយអើយ! ទៅវិញម្តាយសួរហើយ!»

គេស៊ីញ៉ូបុរសនេះហើយខ្សឹបដាក់គាត់៖

«គ្មានផ្លូវឲ្យម្តាយខ្ញុំឃើញទេ! មិនអ៊ីចឹងគាត់ឲ្យឈប់ធ្វើប៉ូលិសភ្លាម!»

ពូហឿនជូតសម្អាតដៃ ហើយហុចគ្រាប់ថ្នាំនឹងដបទឹកមកឲ្យនាយ។

«ញ៉ាំបំបាត់ការឈឺចាប់មួយទៀត តិចទៀតឈឺហើយ! ហើមម៉េចក៏ពីរបីថ្ងៃដែរ!»

ចិត្រាដាក់ទូរសព្ទចុះ ហើយទទួលថ្នាំមកលេបក្អឹកយ៉ាងរហ័ស។ បុរសចំណាស់ញញឹមញញែមរៀបចំប្រអប់ថ្នាំទុកដាក់ទាំងមាត់សាសព្ទមិនដាច់៖

«គ្រួសារជាប៉ូលិសតមកគ្រប់ជំនាន់ហើយ មានរឿងអីដែលថាម្តាយលោកក្មួយមិនជ្រាបពីការប្រឈមមុខរបស់ប៉ូលិស?»

សម្ដីពូហឿន ហាក់ទាញចិត្តគេឲ្យនឹកឃើញឡើងវិញដល់ «លោកមា»។

ត្បិតតែថា ពេលនេះភ្នែកវរសេនីយ៍នៅតែតម្កល់ជាមួយសារចុងក្រោយប៉ុន្មានឃ្លារបស់ឯកមាន។

«មកផ្លូវលេខ៣៣០ កែង២៤៥! ផ្ទះពណ៌ខៀវអត់ផ្លាក! មានដើមចំប៉ាធំមួយនៅកែងខាងត្បូង! ទូរសព្ទអញគេយកទុកអស់ហើយ!»

ចិត្តគេបែរជាបាចសាច រឭលនឹកឃើញដល់ការសន្ទនាជាមួយលោកមាមុនពេលមកប្រទះហេតុការណ៍ល្បួងបញ្ឆោតអ្នកនាងតូចផ្ទះឧត្តមសេនីយ៍។

«ក្នុងពេលដោះស្រាយសំណុំរឿង! គោលដៅភាគច្រើនពុំមែនជាទីកន្លែងទេ តែសំដៅលើមនុស្ស!» «ប៉ូលិសចេញទៅខុសគោលដៅ ឬចេញទៅរកគោលដៅដោយងងឹតងងុល មិនដឹងថាអ្វីជាផែនការ ធ្វើសកម្មភាពបែបណា ពេលខ្លះសូម្បីតែជីវិតក៏យកមកវិញមិនបានដែរ!»

ហេតុអ្វីក៏គិតចុះគិតឡើងវាហាក់បីដូចជាអ្នកណាម្នាក់បានព្យាយាមបង្វែងគោលដៅរបស់យើងឲ្យចេញចោលផ្ទះនេះ?

នេះជាសំណួរដែលគេសួរខ្លួនឯងចុះឡើង ឡើងចុះ។

ប្រសិនបើរឿង SMS នេះ ហើយនឹងការល្បួងចាប់អ្នកនាងអមរាជាអាចទាក់ទងគ្នា តើអាចទេក្នុងការសន្និដ្ឋានថាអ្នកណាម្នាក់បានក្លែងជាឯកមាន ហើយបញ្ឆោតយើងឲ្យចេញចោលភារកិច្ច ហើយគេក៏បានឱកាសចូលមកក្លែងបន្លំបញ្ជាឧត្តមសេនីយ៍នាំអ្នកនាងតូចចេញទៅ?

បើមែន គេនោះជាអ្នកណា ហេតុអ្វីបានជាគេដឹងយើងកំពុងធ្វើអ្វី ហើយអាចស្មានដឹងថា ចិត្តយើងអាចរេចេញចោលពីគោលដៅភារកិច្ចបានដោយគ្រាន់តែឃើញ SMS របស់អាមាន?

មានតែម្នាក់នោះកំពុងដឹងរឿងសព្វបែបយ៉ាង ដឹងថាប៉ូលិសកំពុងធ្វើអ្វី ឯកមាននិងផានូចេញទៅណា ហើយយើងកំពុងត្រូវប្រើឲ្យឃាមកាមអ្នកណា?

ចុះវានោះជាអ្នកណា?

ក្នុងពេលដែលចិត្តតឹងតែងស្មុគស្មាញហត់នឿយ មនុស្សគ្រប់គ្នាចូលចិត្តស្វែងរកដៃគូមកពិភាក្សា ហោចណាស់ក៏ឲ្យបានធូរទ្រូងមួយគ្រាដែរ។

គេងើបមុខសម្លឹងទៅរកបុរសចំណាស់ដែលរៀបចំប្រអប់ថ្នាំទុកទៅក្នុងទូក្បែរជញ្ជាំង។ នេះជាបន្ទប់របស់គាត់ដែលជាអ្នកថែទាំរថយន្ត តែហាក់មានផាសុកភាព មានសណ្ដាប់ធ្នាប់ហើយ មានសឹងថា គ្រប់យ៉ាងសម្រាប់រស់នៅនិងប្រើប្រាស់ បង្ហាញថាម្ចាស់ផ្ទះមានការអនុគ្រោះសន្ដោស បុរសនេះទុកដូចជាញាតិជិតដិតដូច្នោះដែរ។

គេប្រុងហាមាត់បន្លឺទៅកាន់គាត់ ស្រាប់តែនឹកឃើញដូចនៅខ្ចរជាប់ត្រចៀក «នៅក្នុងប្រតិបត្តិការ គ្មានអ្នកណាជាមិត្ត គ្មានអ្នកណាជាញាតិជាផៅ គ្មានអ្នកណាមួយត្រូវជាអ្វីនឹងយើងទាំងអស់!!!»

គេទប់មាត់មកវិញហើយសម្រេចចិត្តថា លែងនិយាយស្ដី។

ចិត្រាដឹងថា ពេលនេះមិនមែនជាពេលដែលត្រូវធ្វើឲ្យរឿងនានា ខ្ចរខ្វាយវែងអន្លាយតាមមនោអារម្មណ៍នោះទេ។ «ដោះស្រាយរឿងក្ដីនីមួយៗ ការវាយតម្លៃរហ័សពេក ប្រើអារម្មណ៍ពេកអាចបាត់បង់ថាមពលអស់ពាក់កណ្ដាលទៅហើយ!!!»

សម្ដីបុរសជាឪពុកមាហាក់ដូចជាមេរៀនយ៉ាងមានតម្លៃទប់ស្កាត់អារម្មណ៍បាចសាចរបស់នាយឲ្យវិលវិញសន្សឹមៗ។

«ត្រូវត្រង់ណាខ្លះវរសេនីយ៍ត្រី?»

លោកឱត សាម៉ុនមកដល់ហើយ។ គេងើបមុខសម្លឹងដំណើរបុរសពេញដោយយសសក្ដិ។ គាត់ចច្រប់ជាមួយការងារអត់បាយទឹក ហើយមកផ្ទះពេលកូនស្រីវិះនឹងភ្លាត់មានរឿងទៀត ក៏អាកប្បកិរិយាបុរសនេះនៅតែខែងរ៉ែងមិនឃើញមានអ្វីប្រែប្រួល។

ទោះបីជាយ៉ាងណា នាយដឹងថាឧត្ដមសេនីយ៍មិនមែនចូលមកដើម្បីតែសួរនាំរឿងរបួសឡើយ។

គេឆ្លើយតបខ្លីៗ

«មិនអីទាំងអស់ទាន!»

បុរសចំណាស់សម្លឹងអង្គរក្សពីលើដល់ក្រោម ហើយឈប់ភ្នែកត្រឹមទូរសព្ទដៃរបស់គេ។

គាត់ឃើញ SMS នៅទីនោះនៅឡើយ។

«បើរបួសមិនអីទេ តោះឡើងទៅបន្ទប់ខ្ញុំពិភាក្សាគ្នាបន្តិច!»

នាយក្រោកឡើងភ្លែត ហាក់បានត្រៀមលក្ខណៈជាស្រេចទៅហើយ។

សំឡេងឧត្តមសេនីយ៍លាន់ឡើងពីក្រោយការចាកចេញរបស់នាយ៖

«តិចទៀតមានប៉ូលិសមកពីរបីនាក់ទៀត! ចាំរៀបចំផងហឿន!»

«បាទទាន!»

មកដល់ក្នុងបន្ទប់ធ្វើការ ចិត្រាឃើញអាហារមួយចាសនៅពីលើតុជាស្រេច។

«តោះ! យើងញ៉ាំផងនិយាយគ្នាផង!»

គាត់ចាប់ផ្ដើមហុចបាយមួយចានមក សឹងថានាយអង្គុយចុះមិនចង់ទាន់។

បុរសចំណាស់នេះធ្វើអ្វីក៏រហ័សរហួនហើយរឹងមាំ។ ពេលនេះដៃគាត់ស្រូបសម្លដាក់ចានខ្លួនឯងផងជជែកប្រាប់វរសេនីយ៍ត្រីផង៖

«នៅផ្លូវ ៣៣០ កែង ២៤៥ គ្មានផ្ទះពណ៌ខៀវ គ្មានដានឯកមានអីទាំងអស់! ប៉ូលិសដែលប្រដេញពីក្រោយក៏គ្មានដានទាក់ទងបាន!»

ដៃចិត្រាកាន់ចានបាយនៅទ្រឹងស្ងៀម ហើយគេនឹកឃើញភ្លាមដល់ទឹកមុខនៃបុរស Hacker ជាមិត្ត។ តាមកាយវិការ និងទឹកមុខនាយគឺកុំថាបាយមួយចាននេះ សូម្បីតែពីរបីម៉ាត់ក៏ប្រហែលអួលទៅមិនរួចដែរ។ គាត់ក៏បន្តដួសសម្លមកស្រូបឲ្យនាយវិញម្ដង អាចថាគាត់ចង់ឲ្យនាយចាំបាច់ត្រូវតែហូបអ្វីខ្លះសិន។

«ពេលលោកផ្ញើសារនោះមក ខ្ញុំឲ្យគេតាមដានភ្លាម! ជំហានដំបូងខាងបច្ចេកវិទ្យាមិនអាចរកឃើញទីតាំងពិតរបស់អ្នកដែលSMS មក បានន័យថាវាមិនមែនជាសាររបស់ឯកមាន ព្រោះថាឯកមានមិនអាចផ្ញើមកប្រថុចញ៉ុច ហើយមានពេលក្នុងការលាក់កំបាំងទីតាំងប្រភពទេ!»

គេរវើក្អែកគិតចុះឡើងត្រចៀកផ្ទៀងស្ដាប់យកចិត្តទុកដាក់មិនហ៊ានតបត។

សំឡេងលោកឧត្តមសេនីយ៍ក្លាយមកជាឡុលៗទំនងផ្ទុកបាយពេញមាត់៖

«ខ្ញុំគិតថាមិនស្រួល ហើយទាក់ទងមកលោកវិញលែងកើត! ខ្ញុំឲ្យ Roy នាំគ្នាគេចេញមកភ្លាម!»

ចិត្រាបើកភ្នែកធំៗហើយហាមាត់ចាប់ផ្ដើមប្រុងនិយាយ ប៉ុន្តែត្រូវបានលោក ឱិត សាម៉ុននិយាយកាត់មុនទាំងបាយពេញមាត់៖

«ហេតុអ្វីគោលដៅរបស់វាគឺកូនអមរាជា? មានតែហេតុផលមួយប៉ុណ្ណោះគឺវាជដៃលហ្នឹងដែលជាអ្នកចាប់ស្រីៗកូននាក់មានបួននាក់មុន?»

«តែវាអាចប្រើឡានមានស្លាកប៉ូលិស ប្រើឯកសណ្ឋានប៉ូលិសនិងប្រើកាំភ្លើងស្នាត់!»

គេប្រញាប់និយាយទៅកាន់គាត់ ព្រោះមិនចង់លាក់បាំងកំណត់សម្គាល់ដ៏សំខាន់ដែលខ្លួនរកឃើញ។

«គេចង់បោកកូនខ្ញុំឲ្យទៅតាម ចាំបាច់ណាស់គេត្រូវប្រើស្រោមជាប៉ូលិស!»

«អ្នកនាងថាឧត្តមសេនីយ៍ទោ សក្តិ ពិសិដ្ឋជាអ្នកខលមកផ្ទាល់ ទើបគាត់ជឿហើយព្រមឡើងឡាន!»

លោកឱិត សាម៉ុនងក់ក្បាលទទួលស្រស្រេបហើយពន្យល់វិញ៖

«គេអាចកាត់តសំឡេងគាត់! ខាងបច្ចេកវិទ្យាកំពុងស្រាវជ្រាវ អំឡុងពេលនោះបណ្ដាញទូរសព្ទរបស់ខ្ញុំ ក៏សង្ស័យថាត្រូវបានលុកលុយចូលហើយកាត់ផ្ដាច់ទំនាក់ទំនងមួយរយៈដែរ!»

សម្ដីនេះដូចជះទឹកមួយផ្តិលចំនាយសក្តិប្អូនយើង។ គេងាកសួរបកមកវិញ៖

«ចុះករណីរបស់អាមាន? អាចដែរទេ? គេផ្ដាច់ទំនាក់ទំនងលេខវា? ទាក់ទងវារាប់សិបដងហើយ ទាក់ទងមិនបាន មិនថាអ្នកនាងផាន្ទ មេនិស្សិតឈុនរាជ… »

លោកឱិត សាម៉ុនងក់ក្បាលតិចៗជំនួសចម្លើយ បង្ហាញថានេះជាការលុកលុយបណ្ដាញទំនាក់ទំនងដ៏ល្បិតល្អន់មួយ។ នាយស័ក្តិប្អូនដកដង្ហើមធំ ហើយដាក់ចានបាយចុះសន្សឹមៗរួចទើបគេនិយាយមួយៗ៖

«ហេតុអ្វីពួកខាងណោះមានសមត្ថភាពបច្ចេកវិទ្យាបណ្ដាញ Internet ជ្រាលជ្រាលម្ល៉េះ? វាមានបំណងអីឲ្យប្រាកដទៅ? ហេតុអីគេអាចក្លែងសំឡេងមេប៉ូលិស ហើយមកបញ្ឆោតឲ្យអ្នកនាងឡើងឡាន?»

«ចុះម៉េចក៏លោកសង្ស័យលើសមាសភាពពួកប៉ូលិសក្លែងក្លាយទាំងនោះបាន?»

គេរវើកគិតចុះឡើងពេលឮសំណួរ។ គេដឹងថាខ្លួនឯងងាកមកប្រុងប្រយ័ត្នខ្ពស់ ក្រោយពេលបានការទូន្មានទាញអារម្មណ៍ពីឪពុកមា តែមាត់គេរៀបរាប់ផ្សេង ព្រោះមិនចង់ទាញឧត្តមសេនីយ៍ចូលនិវត្តន៍មកក្នុងសេណារីយោនេះ។

«ខ្ញុំឃើញ Credit Card និងទូរសព្ទទំនើបៗនៅក្បែរតែកុង! របៀបផឹកកាហ្វេ ប្រភេទកែវកាហ្វេក្នុងឡាននោះ សុទ្ធតែជារបៀបអ្នកមានលុយកាក់ច្រើនហូរហៀរ!»

«តែនេះមិនអាចបង្កើតការសន្និដ្ឋានបាន១០០ភាគរយទេ!»

គាត់តបបកវិញ ដោយមិនចាំបាច់រង់ចាំបន្លាយពេលវេលាយូរ។

ត្រូវឧត្តមសេនីយ៍បដិសេធចំពោះទឡ្ហីករណ៍របស់ខ្លួន ធ្វើឲ្យចិត្រាត្រូវតែចំណាយពេលពន្យល់បកស្រាយបន្ថែម៖

«មួយទៀតគឺការដែលមិនមែនលោកឧត្តមសេនីយ៍ទូរសព្ទមកផ្ទាល់ ហើយខ្ញុំទាក់ទងលោកវិញអត់បាន! គិតរួមជាមួយ SMS របស់អាមាន ធ្វើឲ្យខ្ញុំសង្ស័យទៅដល់ល្បិចនៃការបង្វែងដានមួយ ដែលព្យាយាមទាញខ្ញុំឲ្យចាកចេញប្រញាប់ប្រញាល់ចោលទីនេះ!»

«អ្នកណាជាអ្នកបង្វែងដាន?»

បុរសចំណាស់សួរ ហើយដាក់បង្អែមបាយចូលទៅក្នុងមាត់ទំពាយឺតៗ ទាំងកែវភ្នែករិះគិតចុះឡើង។

ជាមួយនឹងបរិយាកាសស្ងាត់ស្ងៀមគ្មានចម្លើយ គាត់ក៏វាចាកាត់សាញ៖

«បាយទឹកសិនទៅចាំគិតទៀត!»

ចិត្រាពិតជាឮសូរសម្រែកទាមទារសម្ងាត់របស់ក្រពះ ប៉ុន្តែនាយដឹងថា ដាក់អាហារទៅក៏គ្មានរសជាតិដែរ។ ចំពោះមុខ គេគិតម្នាក់ឯងថា បុរសចំណាស់នៅនឹងមុខខ្លួននេះដឹងច្បាស់ពី

ស្ថានការណ៍ដ៏គួរឲ្យយកចិត្តទុកដាក់មួយ គឺអ្នកដែលកំពុងមានចេតនាអ្វីមកលើគ្រួសារនេះ ហើយគេមានស្នៀតកលជ្រៅៗ ដែលចោរធម្មតាមិនអាចទៅរួចទេ។

គាត់ដឹងថាកូនស្រីខ្លួនកំពុងមានគ្រោះថ្នាក់ ថ្ងៃនេះចាប់មិនបាន អ្នកណាធានាថាថ្ងៃក្រោយពួកនោះមិនមានផែនការថ្មី?

គេងើបមុខសម្លឹងគាត់ តែឃើញគាត់កំពុងទំពាញ៉ាំចំៗហាក់គ្មានអារម្មណ៍នៅនឹងគ្រាប់បាយទៅហើយ គឺភ្នែកគាត់កំពុងសម្លឹងទៅកម្រាលតុហើយសញ្ជឹងគិតទៅដល់អ្វីមួយស៊ីជម្រៅ។

«ការសួរចម្លើយប៉ូលិសក្លែងក្លាយទាំងបួនរកឃើញពន្លឺខ្លះទេ?»

គេប្រុងសួរសំណួរនេះ តែសាជាថ្មីត្រូវគាំងព្រោះលោកឱត សាម៉ុន ស៊ីញ៉ូឲ្យគេហូបបាយ។

គេលើកស្លាបព្រាទីមួយមកទំពា។

សុវត្ថិភាពឯកមាននិងនារីរូបស្អាតលើផ្ទះនេះ ធ្វើឲ្យអាហារស្ងួតមកពីណាក៏មិនអាចបង្កើតអារម្មណ៍ស្រេកឃ្លានឲ្យនាយឡើយ តែកុំឲ្យការបារម្ភរបស់បុរសនៅចំពោះមុខអាចរំខានដល់កិច្ចពិភាក្សាក្នុងពេលនេះគេខំប្រឹងលេបឲ្យឆាប់ៗចប់។

«យល់យ៉ាងណាបើពេលនេះខ្ញុំប្រាប់ថា មានករណីបាត់ខ្លួនលើកទី៥?»

នាយស័ក្តិបួននៅស្ងៀមតែសម្លឹងគាត់ត្លៃ។

ចិត្តគេនឹកភ្លាមដល់ផានូដែលចេញទៅជាមួយឯកមាន។ នារីអភិជនចេញទៅជាភ្ញៀវធម្មតា តែទាំងឈុនរាជនិងឯកមានជាអន្ទាក់របស់ប៉ូលិស។

ឬមួយដំណឹងចុងក្រោយគឺពួកគេក៏មានវាសនាដូចអ្នកមុនៗដែលទៅចូលរួមពិធីសមោសរនោះ?

ភាគទី២២

គេនៅស្ងៀមមិនសួរនាំ មិនធ្វើការសន្និដ្ឋានអ្វីទាំងអស់ ព្រោះចិត្តកំពុងជ្រួលច្របល់ ចំណែកគំនិតបញ្ញា សមត្ថភាពយុទ្ធសាស្ត្រ ក៏កំពុងប្រឆាំងគ្នាចម្រូងចម្រាសក្រឡាប់ចាក់ពេញក្នុងគំនិត។

សំឡេងមនុស្សដែលខ្លួនគោរពហើយជឿគាត់គ្រប់សម្ដីគ្រប់ម៉ាត់ កំពុងតែបង្ហើរមកបន្ថែម៖

«...ចិត្រា! ប៉ូលិសខេត្តកណ្ដាលរកឃើញឡានមួយក្រឡាប់ចោលក្រោមស្ពាន! សំខាន់គេជឿថាវាជាឡានស្ព័រពិបាករក មានតែមួយឬពីរគ្រឿងនៅភ្នំពេញ!»

គេងើបមុខសម្លឹងគាត់ ទោះគាត់នៅតែហូប តែគេដឹងថាគាត់ហូបដើម្បីក្រពះ តែចិត្តមិននៅទីនេះដូចខ្លួនបេះបិទ។

លោកឱត សាម៉ុននិយាយបន្ថែមទៀតក្នុងសព្ទសំឡេងខ្សឹបជាងមុន៖

«ក្នុងឡាន ប៉ូលិសរកឃើញលិខិតស្នាមខ្លះជាកម្មសិទ្ធិរបស់នាង Rose កូនថៅមហាវីន!»

ចានបាយលើដៃគេនៅគាំង...

«ប៉ូលិសរកម្ចាស់ឡានមិនឃើញ?»

នាយភ្លាត់មាត់សួរទាំងមិនបានព្រាងទុក។ ប៉ុន្តែឧត្តមសេនីយ៍មិនត្រឹមតែឆ្លើយប៉ុណ្ណោះគាត់ថែមទាំងនិយាយលើស៖

«...ហើយនៅផ្ទះនាង Rose ក៏យើងរកម្ចាស់ផ្ទះមិនឃើញដូចគ្នា!»

ចិត្រាទំពាអាហារយឺតៗ ឯភ្នែកបើកគ្រលួងៗ។

ចំណែកប៉ូលិសចំណាស់បន្តបរិភោគផង បរិយាយបន្ថែមផង៖

«ពេលទៅឆែកឆេរផ្ទះនាង  ប៉ូលិសបានឃាត់ខ្លួន Lorenzo តារាសប្បុរសម្នាក់នោះ!»

នាយស័ក្តិបួនទម្លាក់សមនិងស្លាបព្រាចុះសន្សឹមៗ។

នាយអត់ធ្មត់រង់ចាំសឹងផុតដង្ហើម ទម្រាំគាត់ទំពាចប់ហើយពណ៌នាលម្អិតសេចក្ដី៖

«បើតាមការងារប៉ូលិស ម្នាក់នោះគេចពីត្រូវសង្ស័យមិនផុតទេ! កំណត់ត្រាចុងក្រោយបង្អស់របស់ពិធីការនោះ មុនបាត់ខ្លួនទៅ នាងបានខលរក តារាសប្បុរសLorenzo គឺវាស្រដៀងទៅនឹងពាក្យមហាវីនដែលថាRose និងម្នាក់នោះមានទំនាក់ទំនងគ្នា!»

«Lorenzoនោះមានការអ្វីទៅផ្ទះអ្នកបាត់ខ្លួន?»

«មិនមានចម្លើយនៅឡើយខ្ញុំកំពុងរង់ចាំដំណឹងពីខាងប៉ូលិសមូលដ្ឋានដែលបានធ្វើការសួរនាំគេផ្ទាល់!តែមានរឿងមួយដែលខ្ញុំដឹងច្បាស់គឺ នៅផ្ទះ Rose ប៉ូលិសឃើញជំនួយការ Lorenzo កាន់វត្ថុបុរាណមួយសង្ស័យលួចយកចេញពីផ្ទះរបស់ Rose តែអាណិកជននោះប្រកែកនឹងប៉ូលិសថា គេមករកម្ចាស់ផ្ទះចំពេលដែលចោរប្រុងនឹងលួចរបស់នោះទៅ!»

សម្តីរបស់មហាវីនលាន់រងំឡើងវិញក្នុងអារម្មណ៍ចិត្រាមួយរំពេច។ «ព្រោះខ្ញុំទ័ល! សកម្មភាពមនុស្សម្នាក់នោះនោះធ្វើឲ្យប៉ះពាល់ដល់អាជីវកម្មខ្ញុំ ហើយខ្ញុំក៏មិនដឹងដែរថាគេនិងRose កំពុងធ្វើអ្វីនៅពីក្រោយខ្នងខ្ញុំ?»។

រឿងហេតុដូចជាផ្គួនៗ ស៊ីសង្វាក់គ្នាពេកហើយ។

មហាវីនត្រូវគេលបធ្វើឃាត គេសង្ស័យប្រុសស្រីទាំងពីរនោះ ឥឡូវម្នាក់បាត់ខ្លួន ម្នាក់ត្រូវប៉ូលិសចាប់បាន នៅផ្ទះមន្ត្រីព្រហ្មទណ្ឌកាន់សំណុំរឿងមានករណីចាប់ពង្រត់កូនស្រីផ្ទាល់ ចំណែករាត្រីពណ៌ព្រះចន្ទដំណើរការទៅធម្មតា ហើយសន្ទូចនិងនុយរបស់ប៉ូលិសក៏កំពុងបាត់ដំណឹងទាំងអស់?

បុរសក្មេងដែលស្ងាត់យូរមកហើយ ចាប់ផ្តើមនិយាយស្រាលៗដោយសង្កត់សំឡេង៖

«ច្បាស់ណាស់! អ្នកណាម្នាក់កំពុងនៅពីក្រៅហេតុការណ៍នេះ ហើយវាកំពុងក្រពាត់ដៃចាំមើលយើង! វាកំពុងសើចសប្បាយចំអកយើង!»

គេលាន់មាត់ឡើង ធ្វើឲ្យលោកឧត្តមសេនីយ៍ញញឹមពព្រាយ។

«លោកគិតដូចខ្ញុំ១០០ភាគរយវរសេនីយ៍ត្រី!»

ចិត្រារំភើបចិត្តចំពោះការគាំទ្រដ៏សំខាន់នេះ។ ក្នុងគំនិតរបស់វរសេនីយ៍ត្រីវ័យក្មេងគឺយល់ថាមិនត្រឹមតែមហាវីនឬនារី Rose នោះទេ សូម្បី Lorenzo ខ្លួនឯងក៏កំពុងតែជាកូនអុកត្រូវបានគេប្រើបំភ័ន្តប៉ូលិស ធ្វើឲ្យសាច់រឿងមានលំនាំថាពិធីការ Rose នោះអាចត្រូវតារាសប្បុរសអាថ៌កំបាំងនោះ ប្រើប្រាស់ហើយ ចុងក្រោយពេលមហាវីនរាយការណ៍ទៅប៉ូលិស គេក៏ចាត់ការ នាងបំបាត់ដាន?

សំណួរវិលខ្វាល់ក្នុងអារម្មណ៍នាយ ចំណែកកែវទឹកត្រូវហុចមកដោយគូសន្ទនា។ គេទទួលមកក្រេបទាំងធ្វើមុខស្មើពិចារណា មុនពេលសម្រេចចិត្តចេញការសន្និដ្ឋាន៖

«អាចថា អាម្នាក់ណានោះកំពុងលេងសេណារីយោ! ចង់ឲ្យយើងចាប់ខ្លួន ហើយធ្វើការចោទប្រកាន់លើតារាសប្បុរសម្នាក់នោះជំនួសវា?»

ឧត្តមសេនីយ៍ក្រោកឈរ ហើយបែរទៅបង្អួចសម្លឹងសួនច្បារងងឹតស្រពិចស្រពិលនៅមុខផ្ទះ ទាំងមាត់និយាយបន្តពីសម្តីចិត្រា៖

«លោកធ្លាប់ពិនិត្យក្តីមួយ ដែលដោះស្រាយដោយពូបង្កើតដៃរទេវរសេនីយ៍ត្រី?»

ចិត្រាអង្គុយទ្រឹងហើយរភ្នែកចុះឡើង ឡើងចុះ។ គេគិតម្នាក់ឯងទាំងមាត់ចាប់ផ្តើមឆ្លើយពោលរអ៊ុះៗ៖

«FolderZ22?»

ការជាន់ដានយ៉ាងដំណំរបស់មេធាវីជំនិត នៅឯកូនផ្ទះប្រឌិតសង្កាត់ស្ទឹងហាវ ជារឿងអន្ទាក់ដ៏ស៊ីជម្រៅមួយ ដែលធ្វើឡើងដោយមនុស្សចេះទាំងវិជ្ជាគីមី និងការលុកលុយបណ្តាញ ទម្រាំតែប៉ូលិសរកឃើញការពិត អ្នកពាក់ព័ន្ធនិងអ្នកស៊ើបសឹងស្លាប់សឹងរស់។ ពេលនេះប្រសិនឧត្តមសេនីយ៍ឱិត សាម៉ុន យល់ថា Lorenzo កំពុងជាន់ដានតាមលំនាំរបស់មេធាវីខ្មែរអាមេរិកម្នាក់នោះ តើអ្នកណាអាចដើរតួជំនួសលោកពូខ្លួនក្នុងការស្វែងរកការពិតបាន?

គេឃើញឧត្តមសេនីយ៍បែរមក ហើយច្រត់ចង្កេះសម្លឹងមកខ្លួនថ្មៗ។

គាត់ហាក់ព្រួចម្លើយហើយ តែមិនព្រមនិយាយអ្វី បណ្តោយឲ្យនាយសួរទំហំចិត្តឆ្ងល់៖

«ករណីមេធាវីជំនិត ប៉ូលិសហាក់មានគោលដៅស្រួលកំណត់! ដូចជា គេអាចគិតមុនគេពីទំនាក់ទំនងរវាងគាត់និងប្អូនធម៌ឈ្មោះណិច! គេចុះពិនិត្យតំបន់ដែលជនរងគ្រោះត្រូវគេសម្លាប់! ឃាតករឆ្លាតប៉ុនណា រមែងតែងជ្រុលជ្រួសបន្សល់ស្លាកស្នាមដែលមិននឹកស្មានថាប៉ូលិសរកឃើញ!

តែរឿងលើកនេះ  គ្មានដានគ្មានសល់សូម្បីតែទីតាំងបាត់ខ្លួនមនុស្ស គ្មានកន្លែងប្រាកដថាជាទង្វើសម្រាប់រៀបចំសមោសរ! អ្នកបាត់ខ្លួនម្នាក់ៗគ្មានសាកសព គ្មានតម្រុយ គ្មានអ្នកឃើញ! បណ្តាញទាក់ទងចុងក្រោយរបស់ពួកគេ ត្រូវលុបចោលកំណត់ត្រាទាំងអស់មិនថាទូរសព្ទ internet!»

«អ៊ីចឹងប្រហែលត្រូវអញ្ជើញលោកសេតវិទូ មកជួយក្ដួយប្រុសបំបែកក្ដីហើយ!»

គាត់និយាយទាំងសើចរលាក់ តែចិត្រាមើលឃើញភាពស្មុគស្មាញមួយរយជំពូកលាក់លៀម ក្នុងអាកប្បកិរិយាបុរសជាមេកោយ។

នាយនិយាយមួយៗ តបដៃគូសន្ទនារបស់ខ្លួន៖

«ពូខ្ញុំកំពុងពិសាបាយជាមួយម៉ាក់នៅផ្ទះ! តែគាត់ឈប់ប្រឡូកហើយ! ទោះជួបគាត់ក៏ខ្ញុំមិន ពិភាក្សារឿងដែលនាំឲ្យគាត់ខ្វល់ដែរ!»

សាជាថ្មី ដូចសព្ទដងដែរ ឧត្តមសេនីយ៍ទះស្មានាយធូន់ៗ។

«ខ្ញុំនិយាយលេងសើចទេ! ស្មុគពេកប៉ុណ្ណោះចិត្រា!»

វគ្គ វាសនាឯកមាន

ម៉ោង៧:៣០នាទីយប់

នៅលើដងផ្លូវងងឹតវែងអន្លាយ គោលដៅខាងមុខប្រែទៅជាងងឹតព្រាលទៅៗ ជារឿយៗ។ ឯកមាន ផ្ចង់អារម្មណ៍ទៅរកកញ្ចក់ចំហៀងសម្រាប់មើលទៅខាងក្រោយ។ រថយន្តប៉ូលិសនៅឆ្ងាយឃើញតែពន្លឺតូចៗ តែក៏ល្មមឲ្យរកក់ក្ដៅដែរថា បេសកកម្មនេះពុំមែនប្រថុយពេកនោះទេ។

«ជប់លៀងស្អីគេ ចាំបាច់មកឆ្ងាយពីក្រុងដល់ម្លឹង?»

ឈុនរាជរអ៊ូ។

ឯកមានពិនិត្យតាមដានអាការៈ សម្ដីសំដៅ ទំនាក់ទំនងគេនិងស្រីតូចនេះមើលទៅជិតដិត សមនឹងពាក្យថាគេជាប្រធាននិស្សិតដែលជាទីទុកចិត្តនៃពួកនិស្សិតទន់ខ្សោយផងទាំងឡាយពិតមែន។

ចំណែកផានូញញឹមចិញ្ចាច ដូចតារាត្រៀមរះលើវេហាគង់នាយប់ពណ៌ព្រះចន្ទដែលនាងស្រមៃជាយូរមកហើយ។ ស្រីស្អាតល្បួងអ្នកកំដរផ្លូវ៖

«៣០គីឡូសោះហ្នឹងបង! គេធ្វើកម្មវិធីក្នុង Resort អ៊ីចឹងបានអស្ចារ្យបង!»

ឈុនរាជលែងតបតជាមួយសិស្សប្អូន គេងាកមករក Hacker ដែលថ្ងៃមុនត្រូវធ្វូន់ដៃក្នុងបន្ទប់ទឹកស្រីៗ ថ្ងៃនេះស្រាប់តែក្លាយជាអ្នករួមបេសកកម្ម។

ឯកមានធ្វើមុខស្មើ ដៃបញ្ជាយានយន្ត ភ្នែករំពៃសព្វទិសទី ស្របពេលនារីមើលទូរសព្ទផងបញ្ជាផង។

«បត់ទៅបង! ត្រង់ហ្នឹងហើយ! គេថាបត់ស្ដាំត្រង់ហ្នឹងហើយចូលមួយគីឡូកន្លះទៀត!»

គេបត់ជំនិះតាមសម្ដីស្រីស្អាត តែមាត់នាយនិយាយប្រឆាំង៖

«វាមិនដែលអ្នករោគចិត្តឯណា មកធ្វើកម្មវិធីសប្បាយកណ្ដាលវាលស្រែនោះទេ!»

ផានូពិនិត្យ Google Map ផងមាត់ឆ្លើយតវ៉ាផង៖

«ប្រាប់ហើយថា Resort ឲ្យនៅកណ្ដាលភ្នំពេញ មានពណ៌ព្រះចន្ទពីណាមក!»

«អ្ហូយ ឈ្មោះល្ងោនបាសាក់ជាគ្នា!»

ឯកមានឪនាង។

ឯកមាន បើកបរផងពិនិត្យឆ្វេងស្ដាំផង ព្រោះពេលនេះ ពុំមែនជាដំណើរទៅរកកន្លែងសប្បាយដូចដែលស្រីស្អាតកំពុងតែគិតនោះទេ។ នេះជាបេសកកម្មសម្ងាត់ដែលប៉ូលិសដឹង តែសាមីខ្លួនមិនបានដឹង។ សកម្មភាពពោរពេញទៅដោយសេចក្ដីក្លាហាននាថ្ងៃនេះរបស់ឯកមាន តាមពិតគឺមានហេតុផលមួយចំនួននៅក្នុងការសម្រេចចិត្តរបស់គេ។

រូបរាងស្រីអភិជនឆ្លុះតាមកញ្ចក់ ធ្វើឲ្យបរិយាកាសក្នុងឡានបែរជាស្រទន់ទោះបីសម្ពាយការងារយប់នេះធ្ងន់កម្រិតណាក៏ដោយ។ នាងដឹងត្រឹមថា អមរាជាឲ្យខ្ញុំអង្គរក្ស ហើយប្រធាននិស្សិតតាមមកការពារសិស្សប្អូន។

ម្ដងម្កាល គេលបគយគន់ ភក្ត្រានាងដែលសម្លឹងទេសភាពឆ្វេងស្ដាំឥតនឹងបារម្ភអ្វី ធ្វើឲ្យផ្ទៃមុខទ្រង់គ្រឿងដោយអលង្ការពេជ្រចរណៃភ្លឺផ្លេកៗនោះរឹតតែស្អាតឡើងៗ ដូចទេពធីតាចុះពីទេវលោក។

ដើម្បីរំដោះខ្លួនឯងចេញពីអារម្មណ៍អណ្ដែតអណ្ដូង ព្រោះចិត្តលួចប៉ង់លើដួងព្រះខែឆ្ងាយដៃ នាយប៉ូលិសបញ្ចេញសំណួរតិចៗទាំងមិនមានគោលដៅច្បាស់ថា សួរទៅអ្នកណាម្នាក់ឲ្យប្រាកដ៖

«នៅក្នុងដីកំពង់ស្ពឺនៅឡើយ?»

ស្រាប់តែត្រូវព្រនង់ឌឺដងថ្មោងរបស់ឈុនរាជ៖

«ធ្វើជានុយធំរបស់ប៉ូលិសមានអារម្មណ៍ម៉េចដែរអ្ហ៎ា?»

ឈុនរាជទាបកន្ទើ ខំដាក់សំណួរមកខ្សឹបៗ តែHacker ទទួលអារម្មណ៍ប្រធាននិស្សិតនិយាយស្ដីវាយស្មើហាក់គ្មានការគោរពអ្វីចំពោះនាយជាប៉ូលិសម្នាក់សោះ គួបផ្សំស្នាមអនុស្សាវរីយចាស់ដែលជននេះចេញគំនិតធ្វើឲ្យខ្លួនត្រូវស្រីៗចោមវាយនៅបន្ទប់ទឹកមហាវិទ្យាល័យមិនទាន់បានសងសឹកមួយក្ដារផង គេញាក់ចិញ្ចើមឌឺដង៖

«មានការអី បោះឯងចុះមុនគេ!»

ពីបាំងក្រោយស្រីស្អាតក្នុងឈុតពណ៌ស៊ីជម្ពូស្អាតដូចទេពធីតា កំពុងងើបមុខមកតាមដានការសន្ទនារបស់ពួកគេ។

«បងឯងនិយាយគ្នាអីខ្សឹបៗម៉េះ?»

ផានូសួរទាំងសើចស្វាញបង្ហាញធ្មេញសដូចម្លិះ។ បើកុំតែស្រីស្អាតម្នាក់នេះ ស្មានថា Hacker ឯកមាន ព្រមទទួលយកការងារ ជាអង្គរក្សបន្លំខ្លួនឆ្ពោះទៅរកគោលដៅពិបាកៗរបៀបនេះ?

«បងកំពុងនិយាយលេងជាមួយអង្គរក្សរបស់អមរាដាថា គិតយ៉ាងម៉េចបើកំពុងជិះៗ ពួកអ្នកចាប់ស្រីៗស្រាប់តែបង្ហាញខ្លួន? ដឹងអីម្នាក់នេះគេឆ្លើយថា មានការអីឲ្យបងចុះទៅតស៊ូជាមួយពួកនោះមុន»

នាយឈុនរាជ និយាយផង សើចក្អាកក្អាយដូចជាសប្បាយចិត្តជាខ្លាំងផងផង ចំណែកឯកមានបែរជាយល់ថា មនុស្សកន្ទើចង់ធ្វើឲ្យគេខឹង នឹងអាលបានបញ្ចោះឲ្យគេតបត បាត់ភាពជាអង្គរក្សដ៏សុភាពរាបសាដែលខ្លួនខំពត់កាយវាចាចិត្ត។

គេនេះទំនងមិនដឹងថាឯកមាន ជាប៉ូលិសរបស់លោកឧិត សាម៉ុន ឬយល់ថាឋានៈត្រឹមជាអង្គរក្សតាមហែហមកូនអ្នកមាន បានជាគេវាយសម្ដីលេងឫកដាក់?

Hacker មានវិធីច្រើនណាស់ នឹងអាចប្រើបេសកកម្មនាពេលនេះសងសឹកលើនិស្សិតតូចកន្ទើ្ល តែគេមិនទាន់ធ្វើព្រោះ មូលហេតុដ៏ចម្បងមួយគឺស្រីស្អាតនៅពីក្រោយខ្នងគេ!

អ្នកនាងផានូដ៏ស្រស់ប៉ប្រិម ដែលអង្គុយនៅបាំងខាងក្រោយចោលទាំងក្លិន ចោលទាំងភាពថៃងចាំងនៃសម្រស់ពិបាកនឹងទប់ចិត្តមិនឲ្យរាយមាយ។

សម្លឹងនាងតាមកញ្ចក់មើលក្រោយម្ដងណា ចិត្ត Hacker កាន់តែចង់ជ្រៀតជ្រែកស្វែងរកអាថ៌កំបាំងក្នុងបេះដូងស្រីស្អាត ធ្វើឲ្យគេបែរបន់យ៉ាងណា ឲ្យដងផ្លូវមួយនេះកាន់តែវែងអន្លាយថែមឡើងនឹងអាលមានពេលវេលានៅក្បែរកាយស្រីស្រស់កាន់តែយូរតាមដែលអាចធ្វើទៅបាន។ សំឡេងនាងលាន់មកលាយឡំសេចក្ដីកង្វល់ខ្វល់ខ្វាយ៖

«បងឯងកុំយករឿងអ៊ីចឹងមកនិយាយលេងមើល៍!»

«មានខ្ញុំនៅទីនេះ អ្នកនាងផានូមិនបាច់ខ្វល់អីនាំតែខូចសម្រស់!»

ឯកមាននិយាយតបទៅស្រីស្អាតតាមកញ្ចក់ គាប់ជួននាងក៏សម្លឹងទៅទីនោះដើម្បីតទល់ភ្នែកជាមួយនាយដូចគ្នា។

«បងឯងធ្លាប់ឮរឿងបាត់ខ្លួនទាំងម្ចាស់ទាំងសូហ្វ៊ែរអត់?»

ផានូពោលសួរមកអង្គរក្សលាក់ចិត្តស្នេហ៍ ទាំងទឹកមុខពេញប្រៀបទៅដោយទុក្ខព្រួយចំណែកនាយវិញស្លុងនឹងពន្លឺចរណៃព្រិចៗក្នុងកែវភ្នែកស្រីតូច គាំងរកពាក្យអ្វីឆ្លើយមិនបាននិយាយក៏មិនចេញស្រេចទៅហើយ។

សម្រាប់មនុស្សប្រុសគ្រប់គ្នា ការពារមនុស្សស្រីដែលខ្លួនស្រលាញ់ ធ្វើឲ្យនាងមានអារម្មណ៍ថាមានសុវត្ថិភាពរាល់ពេលនៅក្បែរខ្លួន គឺជាតួនាទីផ្ដាច់មុខមួយដែលខ្លួនចង់ធ្វើជាទីបំផុត។

គេសម្លឹងនាងភ្លឹក ហាក់ចង់និយាយលួងធីតាជាមួយពាក្យពេចន៍ជាច្រើនពីបេះដូងកូនប្រុសទ្រូង៥ហត្ថ ប៉ុន្តែស្នេហាខុសឋានៈនេះ ធ្វើឲ្យឯកមានភាន់ភាំងរួមជាមួយសម្រស់ដូចទេពធីតារបស់កូនស្រីអ្នកមានបង្ហាញមកផ្ទួនៗ រឹងរឹតបណ្ដាលឲ្យចិត្តនាយវង្វេង។

ឈុនរាជឃើញភាពភ័ន្តភាំងនេះអាចយល់ខុសថាអង្គរក្សកំពុងត្រូវបានភាពភ័យរន្ធត់ធ្វើឲ្យគាំងអណ្ដាត ប្រធាននិស្សិតកាន់តែបានចិត្តឌឺដង។

គេនិយាយលាយសំណើចខ្ទរៈ

«មិនមែនតែសូហ្វ៊ីរទេ អាពួកអង្គរក្សក៏បាត់ស្រមោលទាំងអស់!»

ឯកមានឃើញនាងនៅតែសម្លឹងមកនាយទាំងស្រងូត។ ចិត្តគេវិភាគចុះឡើង ដឹងថានារីនេះតាមពិតស្រើបស្រាលនឹងការចូលរួមពិធីដ៏ល្បីនោះតាមភាពជាយុវវ័យរបស់នាង តែនាងក៏មានការភ័យខ្លាចហើយងាយនឹងត្រូវគេពញ្ញាក់ឲ្យបាក់ស្បាតបាន តាមភាពជាមនុស្សស្រីក្នុងរបងមិនដែលចេញដើរហើរស្គាល់សង្គម ស្គាល់គំនិតពោះវៀនមនុស្ស។

គេគេចចេញពីកែវភ្នែកនាង ហើយនិយាយធ្វើហីដាក់ឈុនរាជនៅខាងស្ដាំដៃខ្លួនៈ

«ឲ្យអាចោរម្សៀតនោះបញ្ចេញថ្លើមពាសមេឃផុនវា ហើយមកប៉ះអ្នកនាងផានូមួយសរសៃសក់មក!»

សម្ដីឯកមានចង់ប្រាប់ថា ពេលនេះ នាទីនេះ សេចក្ដីស្រលាញ់ធ្វើឲ្យ Hacker លែងចេះខ្លាចអ្វីទាំងអស់។

ឈុនរាជក្រពាត់ដៃធ្វើមុខជ្រេញ មិនទាន់រកពាក្យមកព្រួសដាក់ស័ក្តិប្អូនបាននៅឡើយ។ ឯកមាន

សាជាថ្មីងើបមុខសម្លឹងទិសដៅភ្លើងពណ៌ខៀវនៅចម្ងាយលឹមៗនៅពីមុខខ្លួន។

គេនិយាយសាជាថ្មីកាត់បរិយាកាសស្ងាត់ស្ងៀមៈ

«អ្នកនាងផានូ ត្រៀមចិត្តសប្បាយរីករាយនឹងពិធីនោះពេញលេញចុះ មានអាមាននៅទីនេះហើយ! ចាំមើលក្រុមបាត់ស្រមោលណាវាមកពាំងឡានខ្លះ? បុកកម្ទេចវាម្ដង!»

គេថាផងដៀងកន្ទុយភ្នែកស្ដាំឌឺដាក់ប្រធាននិស្សិតផង។

«ឯងអាងប៉ូលិសមួយឡានខាងក្រោយហ្នឹងមែន?»

ឈុនរាជនិយាយទាំងមុខក្រញូវ ធ្វើឲ្យឯកមានក្រឡេកទៅឃើញហ្វាឡានប៉ូលិសពិតជាចូលមកកៀកមហាកៀកពិតមែន។

«អ្ហូយ! ឡានពីណាគេបង?»

ផានូក៏ឃើញហ្វាឡានពីក្រោយនោះដូចគ្នា។

នៅលើដងផ្លូវស្ងាត់សូន្យ មានតែរថយន្តពីរបើកមកក្បែរគ្នា បើមិនឲ្យនាងចាប់អារម្មណ៍ម៉េចកើត? តាមពិតមានតែឈុនរាជនិងឯកមានប៉ុណ្ណោះដែលដឹងថាលោកឱិត សាម៉ុនបានដាក់កម្លាំងប៉ូលិសតាមមកមួយឡានជាជំនួយ។

ប៉ុន្តែ... រឿងដ៏សំខាន់ដែលប៉ូលិសស័ក្តិបួនគិតមិនយល់ក្នុងពេលនេះគឺថា តើហេតុអ្វីក៏អ្នកតាមជាជំនួយបង្ហាញខ្លួនមកកៀកយ៉ាងនេះ? ម៉េចក៏គេមិនទៅឯណាឲ្យឆ្ងាយៗទៅ កុំឲ្យមានគេមើលមកដឹងការណ៍បាន?

ឯកមានដៀងភ្នែកគិតទៅតាមគំនិតដ៏វៃឆ្លាតក្លៀវក្លារបស់គេ។

គេមិនទាន់បានចម្លើយផង រថយន្តពីក្រោយបែរជាស៊ីផ្លេហើយបើកហ្វារស៊ីញ៉ូផង។

«ស៊្អីគេអ៊ីចេះ?»

ឈុនរាជរអ៊ូ។

ផានូបែរក្រោយសម្លឹងទៅមនុស្សក្នុងរថយន្តដែលនៅចំពីក្រោយ ហើយកៀកគ្នាបង្កើយ។ នាងលាន់មាត់ប្រាប់ប្រុសៗពីរនាក់នៅខាងមុខ៖

«ប៉ូលិសទាំងអស់!»

ឯកមានដកដង្ហើមយូរហើយចាប់ផ្ដើមថយល្បឿនអែប ទាំងរអ៊ូដាក់ឈុនរាជ៖

«គេមានការស្អីហ្នឹង? ហៅយើងឈប់ធ្វើអី?»

ផានូលាន់មាត់ទាំងរីករាយ៖

«តាមពិតពូសាម៉ុនដាក់មនុស្សតាមការពារខ្ញុំ? អស្ចារ្យណាស់ នាងអមរាដានេះ! មួយម៉ាត់ក៏មិនមាត់ប្រាប់ឲ្យដឹងខ្លួនមុនសោះនៀក! Surprise មែនម៉ង!»

ស្រីស្អាតកំពុងមានអំណរក្នុងអន្លង់នៃភាពខ្វល់បារម្ភរបស់ស័ក្តិបួនឯកមាន។ ជាប៉ូលិសម្នាក់ នាយទទួលអារម្មណ៍ថាអ្វីៗដូចជាចម្លែក។ សភាពការណ៍ហាក់បីដូចជាមិនកើតឡើងតាម គម្រោងដែលបានគ្រោងទុកថា ឡានប៉ូលិសដែលតាមមកត្រូវតែនៅចម្ងាយឆ្ងាយរហូតដល់ គ្មានអ្នកចាប់ថ្នាក់បាន! ចុះហេតុអ្វីពេលនេះត្រដរចូលមកកៀកហើយស៊ីញ៉ូឲ្យឡាន«នាយ» ឈប់។

«គួរឈប់អត់?»

ឈុនរាជងាកមកខ្សឹបសួរ។ ឯកមានបង្ហាញថាគេក៏កំពុងមានគំនិតមិនខុសអ្វីដែល ប្រធាន និស្សិតយើងកំពុងគិតក្នុងចិត្តនោះដែរ។

«បើកកញ្ចក់ខាងឯងទៅ!»

គេនិយាយតិចៗ បញ្ជាឈុនរាជ ព្រោះពីចំហៀងឡានភ្នែកឯកមានដែលតាមដានជាប់ទៅ បរិយាកាសខាងក្រៅ បានមើលឃើញកូនប៉ូលិសម្នាក់រត់សំដៅមក។

ឈុនរាជបែរជាយល់ខុស ហើយនិយាយខឹងវិញដោយទឹកមុខហួសចិត្ត៖

«ថាឯងខ្លាច ខ្លាចមែន!»

និស្សិតល្បីខាងកាងសាលា ពេលនេះផ្តើមចុចបើកកញ្ចក់ចំហៀងខ្លួនឯង ល្មមពេលកូន ប៉ូលិសម្នាក់នោះរត់មកដល់បង្ហាញខ្លួនហត់គយូសក្បែរនោះ។

អ្នកនាងផានូដ៏ស្រស់ផូរផង់ញញឹមសម្លឹងទៅក្រៅហើយសួរនាំភ្លាម៖

«អមរាជាឲ្យពួកបងមកការពារខ្ញុំស្ងាត់ៗ?»

ប៉ូលិសនោះដោះមួកឱនក្បាលគំនាប់គោរពស្រីស្រស់ ធ្វើឲ្យបេះដូងនាងកាន់តែកក់ក្តៅ។

គេបែរមកឃើញកែវភ្នែកមុតថ្លាដែលនាយស័ក្តិបួនសម្លឹងផ្តោតមកក៏មិនញញើត បែរជា និយាយសុភាពទន់ភ្លន់ធ្វើដូចគ្មានរឿងអ្វីកើតឡើង៖

«វរសេនីយ៍ត្រីឯកមាន! មេខ្ញុំចង់ឲ្យខ្ញុំយកប្រដាប់តាមដានទីតាំងមកដាក់បង្កប់ជាមួយលោក ទាន!»

ឈុនរាជឃើញប៉ូលិសនោះនិយាយស្តីដោយក្តីគោរពទន់ភ្លន់ គេក៏បែរមកសម្លឹងឯកមានយឺតៗ មុនពេលសួរម្តបៗ៖

«ពាក់ស័ក្តិប្អូនផង?»

ឯកមានគ្មានពេលចចារជាមួយប្រធាននិស្សិតទាបកន្ទ្បើទេ។ គេក៏លែងរវល់មើលមុខប៉ូលិសនោះព្រោះរវល់ផ្តោតសម្លឹងទៅវត្ថុតូចមួយពណ៌ប្រាក់ដែលកំពុងត្រូវបានហុចសំដៅមក។

វាមានរាងដូចជា USB តែតូចជាងច្រើនដងណាស់ប្រសិនមិនពិនិត្យមិនដឹងថាវាជាវត្ថុអ្វីនោះឡើយ។

ដៃនាយមិនទាន់ទទួលវានៅឡើយ ព្រោះគំនិត Hacker កំពុងគិតទៅដល់រឿងជាច្រើន។ ប៉ូលិសនោះនិយាយមួយៗទៅកាន់ទឹកមុខស្មើធេងរបស់ឯកមាន។

«នៅផ្លូវខាងក្រៅ ពួកយើងបានឃើញឡានទំនើបគួរឲ្យសង្ស័យមួយចំនួន សូមប្រញាប់ភ្ជាប់របស់នេះទៅជាមួយទូរសព្ទរបស់លោក ហើយពួកខ្ញុំនឹងអាចដឹងកន្លែងលោកនៅគ្រប់ជំហាន!»

ឯកមានចាក់សួរបកវិញបន្ទាន់៖

«ហេតុអីឯងស្គាល់ខ្ញុំច្បាស់ ហើយខ្ញុំមិនស្គាល់ឯង?»

គេនិយាយមាំៗដូច្នេះហើយ កូនប៉ូលិសគួរតែញ័រនអាការៈខ្លះដែរ ផ្ទុយទៅវិញតែគេនោះបែរជាប្រកាន់អាកប្បកិរិយា រឹតតែធម្មតា មិនមានថ្លោះទឹកមុខអ្វីទៅតាមការចោទឈ្លេចសួរសោះ។ គេតបវិញហំហាន៖

«មេខ្ញុំប្រាប់ខ្ញុំមិញនេះ ថាអ្នកបើកឡាន ជាវរសេនីយ៍ត្រី មកពីនាយកដ្ឋានចារកម្មបច្ចេកវិទ្យា!»

គេដៀងភ្នែកពិនិត្យប៉ូលិសនេះ។

មួយក្រឡេករបស់គេពីក្បាលដល់ចង្កេះ គេអាចចាំបានភិនភាគម្នាក់នេះច្បាស់គ្មានសល់ទៅហើយ។ ក្រសែភ្នែកដ៏រវៀសរបស់គេ មិនខុសអ្វីពីមធ្យោបាយក្នុងការរុករកលេខកូដរាប់លានដែលគេតែងបង្វឹកខ្លួនឯងជាច្រើនឆ្នាំមកហើយនោះទេ។

ចំណែករបស់ដ៏តូចនោះវាគ្មានគន្លឹះភ្ជាប់ទេ បើយកវាមកដល់ជាប់ទូរសព្ទមានតែវាមានជាតិឆក់ជាប់តែម្តង?

សក្តិប្អូនសើចខឹកហួសចិត្តម្នាក់ឯង ហើយងាកមុខចេញ។

ជាមួយ Hacker ម្នាក់ៗ ការដាក់វត្ថុអ្វីមួយទៅក្នុងកុំព្យូទ័រ ឬទូរស័ព្ទដៃរបស់នាយ ហាក់បីដូចជាកំពុងឆ្កឹះយកពោះវៀននាយចេញមកអ៊ីចឹងដែរ។ ពិសេសនៅក្នុងកាលៈទេសៈរបៀបនេះទៀត!

«កុំសង្ស័យ!»

ឯកមានឆ្លើយបីម៉ាត់ខ្លី ធ្វើឲ្យដៃឈុនរាជដែលប្រុងលូកទៅទទួលវត្ថុនោះមកពិនិត្យត្រូវគាំងហើយដកបកក្រោយវិញយឺតៗ។

ភាគទី២៣

ម្រាមដៃ ឯកមាន ដាក់ទៅលើចង្កូតជាសញ្ញាដេញប៉ូលិសនោះឲ្យថយឆ្ងាយចេញ នឹងអាលគេបន្តដំណើរ ប៉ុន្តែប៉ូលិសនៅតែទទូច៖

«ឆាប់ឡើងពួកវាជិតចូលមកដល់ហើយទាន!»

ឯកមានងើបមុខសម្លឹងទៅក្រោយតាមកញ្ចក់ សំដៅទៅពួកប៉ូលិសក្នុងឡានខាងក្រោយ។

ប៉លិសពីរបីនាក់នៅទីនោះជាមួយឯកសណ្ឋានគ្រប់មុខកំពុងសម្លឹងមករថយន្តមួយនេះ

ដោយពិនិត្យពិច័យ។

គេដកដង្ហើមធំហើយនិយាយខ្លី៖

«ទៅប្រាប់ពួកគេឲ្យនៅឆ្ងាយៗពីខ្ញុំ ហើយបំពេញការងារខ្លួនឯងឲ្យតែល្អ កុំដាច់ខ្សែរយៈជាមួយខ្ញុំទៅបានហើយ!»

គេងាកមុខចេញ ចុចកញ្ចក់ឡានបិទហើយចេញឡានវ៉េវ។

ត្រចៀកនាយ Hacker ឮសូរសំឡេងស្រីស្អាតផាន្ទស្តីឲ្យតិចៗពីក្រោយខ្នង៖

«បងឯងនេះ ស្តាប់គេឲ្យចប់សិនក៏មិនបាន!»

គេមិនរវល់នឹងសម្ដីនាង ហើយក៏មិនខ្វល់ពីឈុនរាជដែលកំពុងតែហុចអ្វីមួយទៅឲ្យនាងដែរ។

ចិត្តឯកមានកំពុងបាចសាចទៅតាមសភាពការណ៍ដែលគេយល់ថា មិនសូវស្រួលសោះ។

ពីកញ្ចក់ឡាន ឡានប៉ូលិសនៅឆ្ងាយទៅៗបានន័យថាពួកគេត្រូវបដិសេធហើយក៏សម្រេចចិត្តមិនតាមមកទេ?

ភ្នែកនាយរេមករកនាឡិកា... ម៉ោង៧:៤៥នាទីទៅហើយ។

ចំណែកប្រធាននិស្សិតគិតពីងាកមកតាមដានសកម្មភាពភាពភាព ឯកមាន មិនថានាយធ្វើអ្វីពិនិត្យអ្វីសម្លឹងអ្វី។

រថយន្តបោលឃឹតៗដូចសង្វាក់បេះដូងអ្នកបើកបរដែលផ្ទុកទៅដោយការសង្ស័យ។ គេឱបចង្កូតរវៃ ព័ទ្ធតាមបណ្ដោយច្រាំងបឹង ដែលរុំព័ទ្ធដោយការដកដង្ហើមតឹងតែងរបស់មនុស្សក្នុងឡានលើកលែងតែអ្នកនាងផានូដែលមើលទៅកំពុងមានជំនឿចិត្តហើយរំភើបរីករាយ។

«អូយ! ខ្ញុំឮសូរភ្លេង!»

ឈុនរាជដែលកំពុងសម្លឹងទៅកញ្ចក់ចំហៀង គេចាប់អារម្មណ៍ថាពេលនេះមិនបានឃើញដានឡានប៉ូលិសទៀតនោះទេ គ្រប់យ៉ាងងងឹតស្លុបសឹងថាសម្គាល់អ្វីលែងដឹង។

«យើងបត់ឆ្វេងផ្លូវនេះមែនអត់បង?»

នារីអភិជនលាន់មាត់សួរមកពីក្រោយ ធ្វើឲ្យឯកមានរំពៃភ្នែកសម្លឹងគ្រប់យ៉ាង ជុំវិញទីនេះដោយរហ័សរហួនស្ទាត់ស្ទៀម។

«ផ្លូវងងឹតម៉េះ តូចម៉េះ?»

ឈុនរាជលាន់មាត់តិចៗ ព្រោះចិត្តសង្ស័យ ប៉ុន្តែស្រីល្អខាងក្រោយបែរជារំភើបនិងអន្ទះសាចំពោះពិធីសមោសរពិសេសសឹងថាភ្លេចបារម្ភនឹងអ្វីគ្រប់យ៉ាង។ ផានូនាងឆ្លើយឆ្លងមកកាន់ប្រធាននិស្សិតវិញដោយមិនបង្អង់យូរៈ

«កន្លែងគេអាថ៌កំបាំងណាបងឈុនរាជ! មិនដឹងខាងក្នុងពិធីអស្ចារ្យយ៉ាងណាទេ!»

បើតាមធម្មតា ឯកមានប្រាកដជាឌីដងឲ្យឈុនរាជវិញតាមរបៀប «ឯងខ្លាច? មិនទាន់យឺតពេលទេ អាចបកក្រោយវិញបាន!»។

ប៉ុន្តែពេលនេះគេគ្មានពេលនិយាយឌីដងទេ ព្រោះតែម្រាមកំពុងរវល់បើកទូរសព្ទដៃ។

«គ្មានសេវា?»

បើតាមសញ្ញាលើអេក្រង់ កុំថាឡើយផ្ញើសារចេញ និងកុំថាឡើយ Internet សូម្បីចង់ខលចេញទៅផ្ទាល់ក៏ពិបាកដែរ។

«នុះផ្លូវ! តោះ បត់ទៅបង! យើងចង់យឺតពេលហើយនៀក ប្រយ័ត្នចូលទៅក្រោយគេ!»

ស្តាប់ឮអ្នកនាងបញ្ជា ធ្វើឲ្យឈុនរាជក្រឡេកសម្លឹងឆ្វេងស្តាំ។ ចំណែកខាងឯកមានដៃគេនៅតែបន្តព្យាយាមជាមួយទូរសព្ទ។

សំឡេងប្រធាននិស្សិតខ្សឹបមករកគេឡុលៗ៖

«នែ៎! បាត់ឡានប៉ូលិសមិញបាត់ហើយ! ឬគេតាមយើងពីចម្ងាយអត់បើកភ្លើងឡានទេ? វាមិនដែលអ្ហ៎»

គេងើបមុខមកវិញសម្លឹងជនកន្ត្លើ ដែលកំពុងខ្សឹបខ្សៀវបារម្ភផង មាត់បឺតទឹកដោះគោកូនក្មេងពីប្រអប់បួនជ្រុងយ៉ាងញាប់ផង។

«ខ្វះជាតិទឹកដោះខ្លាំងម៉េះអ្ហ៎?»

ឯកមានថាផង ដៃម្ខាងបត់ចង្កូតបំបែរទៅតាមបញ្ជាស្រីស្អាតឆ្ពោះទៅទិសខាងជើងទាំងចិត្តស្ទាក់ស្ទើរ ក្រោមស្រមោលរាត្រីកាលងងឹតហត់នឿយភ្នែក។

ប្រធាននិស្សិតនៅតែបន្តក្រេបភេសជ្ជៈចិបចុបផង ងាកមកសម្លឹងគូសន្ទនាជាប់ផង ខណៈដែលមាត់ប៉ូលិសស័ក្តិបួននិយាយខ្លីៗមករកគេបន្ត៖

«យកទូរសព្ទឯង ខលទៅរកឧត្តមសេនីយ៍ឱត សាម៉ុនភ្លាម!»

ឈុនរាជងឿងឆ្ងល់ ហើយរេភ្នែកសម្លឹងទូរសព្ទដែលនៅលើដៃឯកមាននៅឡើយ។ គេឃើញម្រាមដៃHacker នៅតែបន្តចុចតែមិនមានសញ្ញាទាក់ទងបាន។

ប៉ូលិសនេះជ្រួញចិញ្ចើមហាក់ដូចជាចង់និយាយថាការទាក់ទងនៅតែបរាជ័យ ប្រការនេះរឹងរឹតធ្វើឲ្យឈុនរាជប្រញាប់រាវរកទូរសព្ទខ្លួនហើយទម្លាក់កំប៉ុងទឹកដោះគោចោល។

«អូខេចាំមួយភ្លែត! កុំប្រញាប់ពេក ខ្ញុំខលម្ដង!»

ឈុនរាជសាកចុចទៅរកឧត្តមសេនីយ៍ ចំណែកឯកមានងើបភ្នែកសម្លឹងផ្លុះទៅចុងបង្អស់ដែលភ្នែកអាចបាញ់ទៅដល់នៅគោលដៅបុកទៅខាងជើង ប៉ុន្តែគេនៅតែមិនអាចរកឃើញចំណុចពន្លឺណាមួយដូចការរំពឹងទុករបស់ផានូឡើយ។

ឡានបន្ថយល្បឿនរកកលនឹងឈប់…

«ខលមិនចូលទេ! ចុចបីដងហើយ!»

ឈុនរាជរអ៊ូរទាំហើយចុចបន្ត។

«ដឹងថាពេលវេលាសំខាន់ដែរ គាត់បិទទូរសព្ទធ្វើអី? ខ្ញុំចុចទៅអមរាជាម្ដង!»

ទុកឲ្យប្រធាននិស្សិតរអ៊ូ ឯកមានមិនបានតបតអ្វីឡើយ ព្រោះចិត្តគេកំពុងរិះគិតចំពោះអ្វីមួយដ៏ស្មុគស្មាញ។

ក្នុងសភាពនេះ ផានូលូកមាត់មកពីក្រោយខ្នង៖

«ចាំខ្ញុំចុចសាកម្ដងមើល៍!»

គេមិនមាត់ ជាសញ្ញាទុកពេលឲ្យនាងធ្វើ។ ដឹងអីតាមរយៈកញ្ចក់ខាងមុខ ឯកមានក្រឡេកឃើញអ្វីម្យ៉ាងចាំងផ្លេកៗ លើទូរស័ព្ទដៃរបស់ស្រីស្អាត។ រហ័សដូចផ្លេកបន្ទោរ គេងាកក្រោយសម្លឹងនាងខ្ជាប់ ធ្វើឲ្យផានូភ្ញាក់ចិត្តភ័យនឹងភ្នែកនាយ ហើយសន្សឹមៗ នាងទម្លាក់ដៃដែលកំពុងកាន់ទូរសព្ទនោះចុះយឺតៗវិញ។

ឯកមានមិនមែនកំពុងសម្លឹងនាងទេ តែគេផ្ដោតលើ USB ដែលជាប់ឆ្កឹងលើទូរសព្ទរបស់នាង។

បន្ទាន់នោះ គេចោលភ្នែកមករកឈុនរាជដែលនៅក្បែរកាយ ហើយសួរខ្សឹបៗតែសង្កត់ពាក្យកាចៗ៖

«ឯងយក USB របស់ប៉ូលិសមិញឲ្យអ្នកផានូ!»

ឈុនរាជង៉េមង៉ាមដែលត្រូវឯកមានសម្លុតសួរដូចអ្នកទោស។ គេភ្ញាក់ដែលបុរសនេះនៅសុខៗសួរគេដោយទឹកមុខយ៉ាងមាំ។ គេឆ្លើយវិញតតាក់តតុបៈ

«អើ! គេឲ្យឯង ឯងមិនយក យកឲ្យផានូទៅ! មានអីមិនល្អ! ប្រដាប់តាមដានទីតាំងហ្នឹង ក្រែងយើងជួបអីមិនល្អគេមកជួយទាន់ អាចរកយើងឃើញមិនអ៊ីចឹង?»

ឯកមានជាន់ឡានឈប់ងឹត សឹងហើបរបូតអ្នកនាងរូបស្អាតនៅបាំងខាងក្រោយ។ គ្រប់គ្នាចំហមាត់ឆ្ងល់។

គេដៀងភ្នែកទៅរកនាឡិកាឡានដែលលោតចំលេខ 8: 00 pm ល្មម។

«យើងចប់ហើយ!»

បុរសនេះរ៉ុយរៃឡានថយក្រោយពេញទំហឹង ធ្វើឲ្យផានូព្យាយាមតោងកៅអីទាំងប្រហោងពោះ។

«ស្អីគេឯងអាចោរ!»

ឈុនរាជបន្ទោស ព្រោះពេលនេះ ឯកមានបន្ថែមល្បឿនបកក្រោយដូចហោះ។ មាត់នាយបញ្ចាញញាប់ស្មេរៈ

«អា USB នោះ! ប្រាប់ថាកុំឲ្យយក!!»

ប្រធាននិស្សិតងាកក្រោយសម្លឹងមុខនារីនោះដែលកំពុងស្លេកដូចគ្នា។ ពួកគេមិនបាន យល់ស្របអ្វីចំពោះបញ្ហានេះទេ បានជាគ្មានអ្នកណាមានប្រតិកម្មអ្វី រហូតដល់ឯកមាននិយាយមកបន្ថែមមមញាប់ស្មើនឹងល្បឿនឡានដ៏លឿនរបស់គេៈ

«ប៉ូលិសចោលម្សៀតអស់ហ្នឹង វាដាក់ USB បំផ្លាញបណ្តាញទាក់ទងទាំងអស់របស់យើង! គ្មានទូរសព្ទឬកុំព្យូទ័រណាមួយក្នុងឡាននេះអាចប្រើការទាក់ទងចេញក្រៅបានទៀតទេ!»

ផានូចងចិញ្ចើម ប៉ុន្តែឈុនរាជងាកទៅឈោងដណ្តើមយកទូរសព្ទអ្នកនាងអភិជនមកដល់ដៃ ហើយដកយក USB គ្រវែងចេញក្រៅកញ្ចក់។

គេងាកមកវិញទាំងមុខស្លេកងាំង ហើយឱនសម្លឹងទូរសព្ទខ្លួនឯង។ ឯកមាននិយាយមកមួយៗស្រាលៗប៉ុន្តែ តឹងទ្រូងស្ទើរប្រេះ៖

«អត់ប្រយោជន៍ទេ! ប្រព័ន្ធទំនាក់ទំនងទាំងអស់ត្រូវវាចូលលុកលុយបំផ្លាញអស់ហើយ!»

ឈុនរាជតវ៉ា៖

«ដោតតែទូរសព្ទផានូម្នាក់តើ!»

គេជាន់ហ្គែរលឿនជាងមុន ធ្វើឲ្យឈុនរាជតោងឡានស្ទើរផុតជើងពីដី។ ឯកមាននិយាយទាំងខាំមាត់ព្រោះមួម៉ៅ៖

«មិនចេះក៏ដោយឲ្យស្តាប់អ្នកដទៃខ្លះផង! ឥឡូវមិនដឹងមានជីវិតត្រឡប់ទៅផ្ទះអត់ផងទេ!»

ឈុនរាជមិនទាន់បានត សំឡេងអ្វីម្យ៉ាងលាន់មកពីចំហៀងខាងស្តាំដៃ។ បន្ទាប់មកខាងឆ្វេង ខាងមុខ នឹងខាងក្រោយ។

ហ្វូឡានបោលមកពីគ្រប់ទិស ហើយជិតឡើងៗ ទៅតាមដង្ហើមនីមួយៗរបស់អ្នកទាំងបី។

ផានូនឹកឃើញភ្លាមដល់ស្ថានភាពអ្នកនាងៗដែលមានអង្គរក្សជុំទិសផងនៅតែបាត់ខ្លួនបានទាំងមនុស្សទាំងឡាន។

សម្តីជជែកគ្នាជាមួយមិត្តជិតដិតកាលនៅឯមហាវិទ្យាល័យស្រាប់តែលាន់ត្រឡប់មកវិញក្នុងការចងចាំដ៏ស្មុគស្មាញ «ហេតុអី? មានសាក្សីឃើញថា មុនបាត់ខ្លួន ម្នាក់ហ្នឹងចូលសាឡនតែងខ្លួនដល់ទៅបីម៉ោង?» «គេចេញទៅជប់លៀង ហើយក៏បាត់ខ្លួនមែនដែរអត់?» «នែ៎ ផានូ! ចាំយើងឲ្យអង្គរក្សពីរនាក់នោះទៅជាមួយឯង!»

នាងនឹកឃើញដល់ចិត្រា។ អង្គរក្ស២បាត់ម្នាក់ហើយ ថែមជំនួសដោយបងប្រធាននិស្សិតដែលអ្នកណាៗក៏ល្បីថាអាចទទួលដោះស្រាយរឿងរ៉ាវឲ្យសិស្សប្អូនបានសព្វសារពើ តែពេលនេះមើលទៅ គេក៏លែងមាត់លែងកអ្វីកើតហើយដែរ។

«យើងជាអ្នករងគ្រោះទី៥ដែលត្រូវគេចុះកាសែតនៅថ្ងៃស្អែកពិតមែនហើយ!»

អ្នកនាងអភិជននិយាយប្រាប់ខ្លួនឯងស្ងាត់ៗក្នុងចិត្តផង រកកលត្រជាក់ចុងដៃជើងចង់ដួលសន្លប់ភ្លាមៗផង។

«ហើយតើគេចង់ចាប់យើងទៅណា? ស្រីៗដែលបាត់ខ្លួនមុនៗទាំងនោះរស់ ឬស្លាប់?»

ផានូចាប់ផ្ដើមអង្គុយខិតមកមុខ ដើម្បីបានក្បែរកៅអីនៃបុរសទាំងពីរ។

នារីនេះចាប់អារម្មណ៍ឃើញថា ឡានកំពុងបន្ថយល្បឿនស្រីតៗសឹងថាលែងរំកិលទៅមុខ។

នៅក្នុងការស្ដាប់ឮស្នូររថយន្តផ្សេងៗបោលមកច្របល់គ្នាវង្វេងទិស រឿងជប់លៀងសប្បាយបានរសាត់ចេញឆ្ងាយនៅអំណាចសល់ត្រឹមសូន្យភាគរយ ឯគ្រោះថ្នាក់វិញហាក់កំពុងក្លាយមកជាច្បាស់លាស់ ធ្វើឲ្យស្រីស្អាតហាក់បានដឹងពីភាពភ័យរន្ធត់នៃការទទួលកំហុសយឺតពេលទៅហើយ។

ដៃប៉ូលិសសក្តិបួនទាញស្បោងមួយហុចទៅឲ្យប្រធាននិស្សិតចំពោះមុខនាង។ ហើយសំឡេងគេលាន់មកខ្សឹបៗល្មមតែឮបីនាក់៖

«ចាំ! អ្នកណាក៏ដោយ ក្នុងចំណោមពួកយើង! ឲ្យតែបានទាក់ទងដល់ចិត្រាឬលោក ឱត សាម៉ុនពាក្យដំបូងគេដែលត្រូវប្រាប់អ្នកទាំងពីរនោះគឺថា អ្នកចាប់យើងជាប៉ូលិស!»

ឯកមានចង់និយាយថា អ្នកចាប់ស្រីទាំងបួនលើកមុនៗក៏ជាស្នាដៃប៉ូលិស? ដោយសារអ៊ីចឹងមែនទេបានជាគ្មានអ្នកណាអាចបំបែកសំណុំរឿងដ៏កក្រើកនេះបាន? ឈុនរាជគិតពាក្យប៉ុន្មានឃ្លានេះទាំងភ្នែកក្រឡេបក្រឡាប់ ប៉ុន្តែពេលវេលាមិនអនុញ្ញាតឲ្យគេសួរបញ្ជាក់ឡើយ។

គេទទួលស្បោងពីដៃឯកមានមកបើកមើល ឃើញក្រណាត់សូត្រភ្លឺទែងមួយសំណុំហើយចុងក្រោយសក់ស្រីក្លែងក្លាយមួយដ៏វែងខ្មៅក្រើប។

«ឯងមិនមែនចង់ឲ្យយើងបន្លំជាអ្នកនាងផានូទៅរងគ្រោះជំនួសនាងទេអ្ហី?»

គេគិតតែសួរ បែរជាងាកមកយ៉ាងរហ័សសម្លឹងមុខនាយ។

«ស្រាយយកមកឲ្យខ្ញុំ!»

នៅចំប្រលោះកណ្ដាលរវាងបុរសទាំងពីរ ផានូកំពុងចុចទូរសព្ទចុះឡើងមិនឈប់ឈររហូតដល់បញ្ចេញកំហឹង «ហ៊ឺះ!» គឺបានន័យថាការហៅចេញពីក្នុងឡាននេះគ្មានបានការទាំងអស់។

«យើងគិតម៉េចទៅ?»

ផានូស្លួរញ័រៗ ធ្វើឲ្យឯកមានដៀងភ្នែកសម្លឹងនាង។ បេះដូង Hacker ដាច់ដោចរុះរោយ។ ជីវិតនាងសឹងថា សំខាន់ជាងអ្វីៗដែលសក្ដិបួនមាត់អាក្រក់ម្នាក់នេះធ្លាប់គិតសម្រាប់ខ្លួនឯង។ គេសម្លឹងនាងជាមួយកែវភ្នែកស្រទន់ ហាក់ចង់ប្រាប់ថាទន្សាយនឹងឆ្ងាយដួងព្រះចន្ទហើយតើមែនទេ?

វាក៏ជាការសម្លឹងចុងក្រោយ ដែលនាយមិនដឹងថាតើអាចជួបនាងសាជាថ្មីដែរ ឬអត់ទៀតនោះឡើយ។ នារីនេះបញ្ចេញការបារម្ភជ្រាលជ្រៅតាមពន្លឺភ្នែកទាំងសងខាងដែលជះរស្មីព្រិចៗដោយអ្វីសើមៗ៖

«មិញបងថា មានបងឯងនៅទីនេះ  ខ្ញុំមិនបាច់ខ្វល់អីនាំតែខូចសម្រស់! មិនអ៊ីចឹង?»

Hacker ខាំមាត់ ងាកមុខចេញហើយនិយាយ៖

«ឃុនរាជ ពីរបីដង្ហើមដែលខ្ញុំពន្លត់ភ្លើង ឯងត្រូវនាំអ្នកនាងរត់ចេញពីឡានហើយលាក់ខ្លួនក្នុងកន្លែងងងឹតៗ។ ជួយពាក់សក់នេះ ហើយគ្របសូត្រនៅកៅអីក្រោយ! ខ្ញុំចេញទៅបញ្ឆោតពួកវា!!»

គេនៅស្ងៀមមួយដង្ហើម ដូចទុកឱកាសឲ្យខ្លួនឯងមុននិយាយពាក្យថា«លា»។ ចំណែកឯប្រធាននិស្សិតនៅគាំងអណ្ដាត លែងនិយាយចេញ។

គេរេភ្នែកសម្លឹងតំបន់នេះ។ ភ្លើងមួយគ្រាប់មកពីចម្ងាយក៏គ្មាន ផ្ទះអ្នកស្រុកនៅឯណាទៅ?

ឃុនរាជនៅពិចារណាវិលខ្វាល់ ចំណែកផានូវិញរង់ចាំទម្រាំឮឯកមាននិយាយមកទៀត៖

«អ្នកនាងផានូ! ឃុនរាជនឹងនាំនាងទៅពួន! ខ្ញុំចេញឡានទៅមុន ហើយពួកវានឹងដេញតាមខ្ញុំ!»

«បងឯងដាក់សក់ក្លែងក្លាយនេះបន្លំថាជាខ្ញុំ?»

នាងស្លួរញ័រៗ តែគេមិនឆ្លើយ ព្រោះក្រឡេកទៅ គេពិតជាធ្វើតាមលឿនណាស់ ថែមទាំងអាចបន្លំបានពិតមែន។ គេនិយាយទៅកាន់នាង ដែលខិតមកសឹងថាក្បែរច្រមុះជគ្នា៖

«ខ្ញុំបើកឡានសម្រុកទៅ ហោចណាស់ក៏បង្វែងដានពួកវាបានបួនប្រាំនាទីដែរ!»

«តែបួនប្រាំនាទីទេអ្ហី?»

គេដឹងថានាងភ័យ ទើបនាយស្រដីបន្ថែម៖

«អ្នកនាងត្រូវតែក្លាហាន ទៅជាមួយឈុនរាជ កាន់តែលឿនកាន់តែល្អ! កាន់តែឆ្ងាយកាន់តែសុខ! ត្រូវចាំថា ទីណាក៏ដោយឲ្យតែរកបានទូរសព្ទ ត្រូវទាក់ទងទៅលោកឱត សាម៉ុនភ្លាម!»

នាងញ័រដៃ ហើយស្លេកមុខសម្លឹងនាយ។ ពេលនេះ ទោះចង់យំក៏យំមិនប្រាកដថាចេញដែរ។

ដៃនាយហុចអាវក្រៅខ្មៅក្រឹបមកឲ្យ។

គ្រប់យ៉ាង Hacker ហាក់ត្រៀមបានល្អណាស់។ ជាមួយអាវនេះ នាងអាចនឹងបន្លំខ្លួនក្នុងភាពងងឹតបាន។ ដូច្នេះស្រីស្អាតដឹងដោយមិនបាច់រង់ចាំការពន្យល់ច្រើនថា នាងចាំបាច់ត្រូវតែចុះ។

ផានូរលើងរលោង ឱនចងជាយសំពត់សូត្រវែងអន្លាយ ដែលមុននេះសង្ឃឹមថាបានស្គាល់សមោសរពណ៌ព្រះចន្ទ ដឹងអីវានឹងត្រូវពាក់សម្រាប់កំដរការរត់លូនទៅវិញសោះ។

«ចាំផ្លូវដែលយើងចូលមកមុននេះដែរអត់? កុំចេញទៅផ្លូវនោះ ត្រូវរកផ្លូវវាង ផ្លូវកាត់អូខេ?»

គេងាកមកនិយាយបញ្ជាក់ជាមួយឈុនរាជ ដែលនៅស្ងាត់មាត់ដូចចោរលួចសេះ។

ភាគទី២៤

ឡានចាប់ផ្តើមបន្ថយល្បឿន ហាក់ដូចបង្ហាញអ្នកទាំងពីរថាពេលវេលាអស់ហើយ។ សំឡេងឈុនរាជជ្រែកកាត់ភាពស្ងប់ស្ងាត់តឹងទ្រូង៖

«បងមិនអាចធ្វើបានទេផានូ! បងជាអ្នកបើកឡានទៅបង្វែងដាន ឯងទៅជាមួយអាប៉ូលិសនេះចុះ!»

ឯកមានសម្លឹងគេ គេងាកមកនិយាយបន្ថែម៖

«បើឯងបានការមែន នាំនាងទៅឲ្យដល់ផ្ទះវ៉ី!»

គេនៅស្ងៀម ព្រោះមិនដឹងថាហេតុអ្វីបានជាអ្នកបៅទឹកដោះដូចកូនក្មេងម្នាក់នេះមិនចង់រត់ បែរជាចង់ប្រឈមនឹងពួកមនុស្សដែលទើបនឹងមកដល់?

ឈុនរាជពន្យល់ប្រញាប់៖

«ឯងឃើញហើយ យើងជាមនុស្សទាបកន្ទឿជើងខ្លី នាំផានូទៅ មានតែនាំឲ្យនាងរត់ឃើត!»

ហេតុផលនេះនៅតែមិនអាចធ្វើឲ្យទឹកមុខនាយស័ក្តិបួនប្រែប្រួលបាន ម្ល៉ោះហើយឈុនរាជនិយាយបង្ហើយ៖

«បានហើយ ឈប់បន្លាយពេលទៅ យើងសារភាព យើងគ្មានសមត្ថភាពនាំផានូចេញផុតពីតំបន់ចង្រៃនេះទេ! យើងពឹងលើឯង! ទៅៗកុំគិតពីកន្លែងនេះ!»

ឯកមានដកដង្ហើមធំ។

ទីបំផុត គេគិតយល់ហើយ។ ឈុនរាជពិតជាមនុស្សយល់ការ ហើយមិនសាំញ៉ាំ ដូច្នេះបានជាគេក្លាយជាអ្នកដោះស្រាយបញ្ហាដ៏ល្បីប្រចាំសាលា។ ពេលនេះទើបឯកមានដឹងថា មនុស្សទាបកន្ទឿម្នាក់នេះមានចិត្តមោះមុត មិនចេះខ្លាចនរណា ហើយមានចរិតទទួលខុសត្រូវខ្ពស់ មិនទន់ខ្សោយកំសាកសូម្បីតែបន្តិចណា។

«ឯងខ្លាចទេ?»

គេសួរទាំងសើចតិចៗ ទៅកាន់មេនិស្សិតដែលមុខក្រញូវ។ ឈុនរាជពិតជាបានសម្រេច ថាបំបុកទៅរកឡានទាំងប៉ុន្មាននោះ ដោយគ្មានរុញរាទេក្នុងកែវភ្នែកឯកមាន។

«មនុស្សយើងគ្មានអាណាជៀសងាប់រួចទេ! មុនក្រោយគង់ងាប់! ងាប់ក្លាហានបន្តិចវាគ្រាន់ជាងកំសាកញី!»

គេឆ្លើយហើយលូកដៃរុញច្រានប៉ូលិសឲ្យចេញពីកន្លែងអង្គុយ។

ហ្វាឡានបាញ់មកពីចម្ងាយ។ វាខ្លាំងប៉ុណ្ណាទំនងជាមិនទាន់មើលអ្វីៗនៅទីនេះច្បាស់នៅឡើយទេ ប៉ុន្តែក៏មិនមានពេលយូរទៀតដែរ បើតាមសម្រែកម៉ាស៊ីនរោទ៍កណ្តាលរាត្រីស្ងាត់។

កង់ឡានឈប់ងឹត ឯកមានពន្លត់ឡានហើយលោតចុះ  ចំណែកឈុនរាជដូរមកទីតាំងបើកបរ ហើយពោលជំរុញផានូបន្ថែមយ៉ាងរហ័ស៖

«ចុះទៅ! ឯងមិនអាចក្លាយជាអ្នកបាត់ខ្លួនទីប្រាំទេ!»

នាងស្រក់ទឹកភ្នែកសម្លឹងប្រធាននិស្សិត គ្រប់យ៉ាងងងឹតស្លុបគ្មានអ្នកណាមើលអ្នកណាឃើញទៀតឡើយ។ ឯនៅខាងឆ្វេងដៃ ទ្វារឡានបានរបើក ហើយដៃឯកមានលូកមកទាញនាងឲ្យចុះចេញ។

គេនិយាយស្រាលៗជំនួសចិត្តខ្លោចផ្សាររបស់នារីនេះ៖

«ឯងកន្ត្រៃតែចិត្តឯងសាហាវ! សុំគោរព! ហើយមិនបាច់ឆាប់ស្លាប់ពេកទេ នៅជំពាក់គ្នា មិនទាន់បានទូទាត់ផងរ៉ុ! ចេញឡានទៅ!»

ឡានរោទ៍ង៉ោង ទាំងគ្មានពន្លឺភ្លើងមួយសរសៃ ឯហ្វាបួនទិសបាញ់មកជិតឡើងៗ...

ដៃស្រីស្អាតត្រជាក់ស្រេប... ជើងនាងរត់លឿនទាំងមិនបានប្រឹងព្រោះកម្លាំងប៉ូលិសអូសនាំ។ នាងមិនដឹងថា ទីនេះមានអ្វីខ្លះហើយឆ្ពោះទៅណា ដឹងតែថាបេះដូងនាងនៅជាប់និងប្រធាននិស្សិត។

«គេធ្វើបាបគាត់អត់?»

នាងយំហើយ។ នេះបើតាមសព្ទសំឡេងរបស់នាងដែលសួរមកខ្សឹបៗ ប៉ុន្តែឯកមានមិនបានតបអ្វីព្រោះគោលដៅសំខាន់របស់គេគឺស្វែងរកទីមានសុវត្ថិភាព...

វគ្គ ចម្លើយមហាវីន

«Rose បាត់ខ្លួនតាំងពីយប់មិញ!»

មហាវីនដែលកំពុងអង្គុយសំកុកលើគ្រែពេទ្យ ហើយសម្លឹងទៅរកខាងក្រៅ ព្រោះគេគិតថាមានសេរីភាព ពេលនេះប្រញាប់ងាកមករិញយ៉ាងលឿន។

សម្ដីលោកឱត សាម៉ុនបន្តមួយៗ ហើយម៉ាត់ៗ តែប្រើសំឡេងខ្សោយឆ្លើយតបទៅនឹងកែវភ្នែកស្លន់ស្លោរបស់ជនកន្ទាត់៖

«ប៉ូលិសខេត្តកណ្ដាលរកឃើញឡានពិធីការរបស់លោកក្រឡាប់ចោលក្រោមស្ពាននៅតាខ្មៅ!

លិខិតស្នាមរបស់នាង Rose នៅនុះទាំងអស់ តែម្ចាស់ឡាននៅគ្មានដំណឹងដល់ពេលនេះ!

យប់មិញប៉ូលិសបានចូលទៅដល់បុរីដែលនាងរស់នៅ គ្មានស្រមោលនាង Rose ហើយក៏គ្មានដំណឹងអ្វីទាំងអស់! សន្តិសុខនិយាយថានាងមិនចូលផ្ទះតាំងពីព្រឹកមក បានន័យថានាងមកទីនេះមើលលោកពេលលោកសន្លប់ហើយតមកនាងក៏បាត់ខ្លួន!»

មហាវីនងាកមុខចុះឡើងដោយបើកភ្នែកធំៗសម្លឹងប៉ូលិសដែលមានតែពីរនាក់គត់ក្នុងបន្ទប់នេះ។ ម្នាក់គឺលោកឱត សាម៉ុន ដែលកំពុងតែធ្វើការពិពណ៌នាហេតុការណ៍ទាំងអស់ទាក់ទងនិងនាង Rose មកប្រាប់គេ ចំណែកម្នាក់ទៀតគឺកូនប៉ូលិសស័ក្តិបួនដែលសម្លឹងមកគេពិនិត្យពិច័យសឹងថាចង់ឲ្យឃើញធ្លុះដល់ឆ្អឹង។

«មើលខ្ញុំធ្វើអី?»

គេសម្លុតមកចិត្រាវិញ ទាំងខ្លួនឯងកំពុងភ័យផ្អែមមាត់។ លុះឃើញចិត្រានៅតែមិនព្រមដកចយក្រសែភ្នែក ដែលកំពុងតែពិនិត្យតាមដាននោះចេញ ជននេះនិយាយបន្ថែមហាក់ខឹងផងស្លន់ផង៖

«ខ្ញុំដេកស្តិនៅទីនេះជិតពីរថ្ងៃហើយ ទូរសព្ទមួយគ្រាប់ក៏អត់មានប្រើ ខ្ញុំមិនពាក់ព័ន្ធទេ!»

ចិត្រាងាកមុខចេញពិនិត្យជុំវិញបន្ទប់នេះទាំងដកដង្ហើមវែង។ ពេលងាកមកវិញគេនិយាយ៖

«បើលោកមិនសហការជាមួយប៉ូលិស បន្ទប់នេះក៏ការពារលោកមិនបានយូរប៉ុន្មានដែរមហាវីន?»

នាយនិយាយទាំងមិនបានការអនុញ្ញាត មិនបានព្រាងទុក ប៉ុន្តែហាក់មានល្បិចចិត្តសាស្ត្រប្រាកដច្បាស់ក្នុងការបង្ខំជននេះឲ្យកាន់តែតក្កមា ក្នុងពេលវេលាខើចខ្លីមិនបាច់ចំណាយរង់ចាំឆ្លើយឆ្លងយូរ។

សភាពនេះ ដូចគ្នាបេះបិទនិងចរិតលក្ខណៈរបស់ប៉ូលិសសេត វិទូដែលលោកឱត សាម៉ុននៅចងចាំបាន។ ឧត្តមសេនីយ៍ងាកមកលបលួចអង្កេតអាការៈប៉ូលិសក្មេង។

គេលង់ទៅក្នុងការអង្កេតសំណុំរឿងពេក ដល់ថ្នាក់មិនបានចាប់ភ្លឹកខ្លួនឯងឡើយថា ការសួរចម្លើយរបស់គេគេ កំពុងប្រាសចាកពីចរិតពិតរបស់គេពេលធម្មតា។

តែសម្រាប់មហាវីនវិញ សម្ដីត្រឹមប៉ុន្មានម៉ាត់នេះ ពិតជាមានអនុភាពធ្វើឲ្យគេអង្គុយលែងសុខ។ កើតមកជាអភិជនសោយសុខសម្បូរសប្បាយ នៅសុខៗដោយសារតែល្បែងសមោសរមួយដើម្បីតែភាពរំភើបឲ្យអ្នកផង នឹកសរសើរ ទីបំផុតត្រូវមកផុងខ្លួនក្នុងអន្ទាក់គ្មានមុខចំណេងសម្រាប់ស្រាយចេញមួយនេះ តើឲ្យគេនៅសុខម៉េចនឹងបាន?

ការពើតឈើមុខរបួសកាន់តែរើមក ពេលអារម្មណ៍បុរសអ្នកមានម្នាក់នេះលែងនឹងន។ គេនឹកដល់សម្ដីកាលពីល្ងាចម្សិលដែលប៉ូលិសបន្សល់ឲ្យ «ប្អូនគ្រាប់ដែលគេឲ្យលោក គឺគេមិនចង់ឲ្យលោករស់ទេ! លាក់ខ្លួននៅទីនេះក៏មិនមែនរឿងគ្រប់គ្នាចង់ធ្វើដែរ តែបើយើងរកមនុស្សអស់នោះនិងអ្នកនៅពីក្រោយមិនបាន លោកនឹងគ្មានសុវត្ថិភាពជារៀងរហូត!»

មហាវីនតាមពិតពុំបានធ្វើពុតដូចពីម្សិលទៀតឡើយ គេពិតជាកំពុងបុកពោះ ទោះជាគេខំរក្សាកាយវិការនឹងន។

បានសាក្សី ស្លុងក្នុងភាពបារម្ភហើយ លោកឱត សាម៉ុនចាប់ផ្ដើមនិយាយបន្តមួយៗតទៅទៀត៖

«ចម្លែកត្រង់ថា Lorenzo ទៅរក Rose ដល់ផ្ទះទាំងយប់ ហើយក៏ត្រូវប៉ូលិសទៅទាន់!»

មហាវីនបើកភ្នែកធំៗសឹងប៉ុនពងមាន។ បរិយាកាសស្ងាត់ស្ងៀមមួយខណៈដែលអ្នកទាំងបីចំណាយពេលពិនិត្យតាមដានអាការៈគ្នាទៅវិញទៅមក។ ចុងក្រោយ អ្នកដែលហើបមាត់ទម្លុះភាពស្ងាត់ស្ងៀមគឺមហាវីន។

នាយសម្បូរទ្រព្យ ពោលខ្សាវហាក់គ្មានកម្លាំងកំហែង៖

«បើគេនោះស្ថិតក្នុងដៃប៉ូលិសហើយ មិនប្រញាប់សួរចម្លើយទៅ មកទីនេះនាំឲ្យខាតពេល!»

លោកឱត សាម៉ុន ដៀងភ្នែកសម្លឹងចិត្រា ធ្វើឲ្យនាយស័ក្តិប្អូនបញ្ចេញវាចាមកជំនួស៖

«គ្រាន់តែឃើញគេនៅក្រៅផ្ទះអ្នកបាត់ខ្លួន យើងអាចសុំគេសហការឆ្លើយសំណួរខ្លះ តែយើងគ្មានហេតុផលគ្រប់គ្រាន់ក្នុងការឃាត់គេទុកដើម្បីសួរចម្លើយទេ!»

មហាវីនហាក់ខឹងនៅពេលឮថា Lorenzo នៅតែមិនអី។

គេចងចិញ្ចើមសួរបកដោយមិនខ្វីមើលមុខអ្នកណាម្នាក់៖

«ចុះខ្ញុំ? ខ្ញុំខុសអី បានជាត្រូវគេមកសួរចម្លើយទាំងរិលមុខខ្វាល់មិនទាន់ដកសេរ៉ូមនៀក?»

«ព្រោះលោកជាអ្នកបង្កើតសមោសរនោះឡើង ហើយចុងក្រោយលោកមិនដឹងថាកម្មវិធីនៅដំណើរការហើយ តើអ្នកណាជាអ្នកគ្រប់គ្រងផង! ចំណែកពិធីការរបស់លោកបែរជានៅសុខៗបាត់ខ្លួន »

ចិត្រាឆ្លើយលឿនពេក ច្បាស់ពេក ធ្វើឲ្យបុរសអ្នកមានប្រាក់មិនអាចរកអ្វីមកតវ៉ាកើតតែម្តង។ ពេលនេះមហាវីននៅស្ងៀមធ្វើភ្នែកភ្លឺះៗ សម្លឹងតែមគ្រែ ទុកឲ្យចិត្រានិយាយបន្ត។ បុរសស័ក្តិប្អូនឱនមកឲ្យជល់មុខនិងជននេះ ព្រមទាំងខ្សឹបប្រាប់គេះ

«មានតែលោកព្រមនិយាយការពិតពីសកម្មភាពទាំងអស់របស់ Lorenzo ទើបប៉ូលិសមានភស្តុតាង អាចឃាត់គេមកសួរចម្លើយបាន!»

មហាវីននៅស្ងៀមបិទមាត់ដូចគេចុក ប៉ុន្តែកែវភ្នែកគេទាំងសងខាងឆ្លេឆ្លាក្រឡាប់ចាក់….

ពិតមែនតែការស្រាវជ្រាវគឺជាកាតព្វកិច្ចស្នូលនៃប្រតិបត្តិការស៊ើបអង្កេតទាំទាំងឡាយ ប៉ុន្តែវិធីនិយាយផ្ទាល់ ជាមួយជនរងគ្រោះ មិនថាខាងសាក្សី ខាងជនសង្ស័យរឹតតែមានប្រសិទ្ធភាពទ្វេ បើធៀបទៅនឹងវិធីស្រាវជ្រាវដទៃទៀត។

ជាទូទៅ កងកម្លាំងប៉ូលិសចាំបាច់ត្រូវមាន ធនធានជាអ្នកជំនាញផ្នែកសម្ភាសន៍ដែលទទួលបានការបណ្តុះបណ្តាលច្បាស់លាស់ ប៉ុន្តែមុនពេលសាកសួរ ពួកគេក៏ត្រូវតែដឹងរឿងហេតុឡើងវិញពីដើមដល់ចប់ គឺប្រើពេលវេលាវែង។

ដូច្នេះហើយ ពេលនេះដោយសារសម្ពាធពេលវេលា លោកឱត សាម៉ុនជ្រើសយកការសាកសួរនៅបន្ទប់ព្យាបាលនេះ ជំនួសឲ្យការសាកសួរផ្លូវការទៅលើមហាវីន។